# រក្សារចនាប័ទ្មខ្មែរឲ្យបានគង់វង្ស

# Carrying Khmer style into the future



**Angkor Wat** Artie/Flick Creative commons



**French studies building at RUPP** Sovan Philong




Local Khmer architecture → New Khmer architecture → What's next?

**Sun Narin, Touch Sopor and Ngo Menghourng**

Construction in Cambodia has been booming in the last decade, and despite the economic crisis, the modernising of Cambodia's urban centres has continued to progress at a steady pace. Although the last 10 years have seen unprecedented growth in Cambodia's cities, many of the buildings have been designed by foreigners, raising concern among Cambodian architects and historians that the country's modern buildings are lacking Khmer style and causing cities in the Kingdom to lose their cultural identity.

Chea Bunseang, the principal architect at Bunseang Architects and Associates, said Cambodian architects lack the skills and practical experience due to out-of-date programmes at the Kingdom's architectural schools, a lack of comprehensive building codes and zoning codes, and a lack of professional architecture instruction or an architecture society to act as a support network for designers working in the public and private sector.

Loy Bunleng, a 22-year-old architecture student in his fourth year at Norton University, said he is concerned that too many foreigners are being brought in to design buildings.

He suggested that the government should "encourage Cambodian architects by giving them a chance to show their ideas, because we are capable of drawing good plans for the building".

Besides missed opportunities for the Kingdom's emerging architects to hone their skills, the lack of Cambodians designing the country's new buildings is also jeopardising the traditional identity of Cambodia's urban centres.

"We all want the buildings, especially the state buildings, to be representative of traditional Khmer culture," said Tang Sochet Vitou, an architecture lecturer at Royal University of Fine Arts, explaining that, as opposed to foreigners who have minimal understanding of traditional Khmer architecture, Cambodian architects have precise styles that are representative of Khmer identity. "We are creative and retain the originality of Khmer characteristics. I want our architects to show their attainment like Vann Molyvann."

Vann Molyvann was the pioneer of "new Khmer architecture", which emerged during the French colonial era in the 1950s, and he has since established himself as the country's most famous contemporary architect. Over the last five decades, he has designed many of Phnom Penh's most recognisable buildings. Some of his designs, such as the Independence Monument, have obvious similarities to ancient Cambodian architecture, while others, such as the Chaktomok Theatre or Olympic Stadium, feature more modern designs and subtle Khmer characteristics.

Vann Molyvann is one of many Khmer architects who have taken modern designs and integrated traditional Cambodian building styles to create new styles that preserve the aesthetic traditions and functionality of traditional buildings. The French Department at the Royal University of Phnom Penh (pictured above), designed by Vann Molyvann, is an obvious example. The moats that surround the modern-looking building are an homage to the moats that surround Angkor Wat and other temples.

"Other countries don't have these buildings," said Hok Sokol, a Cambodian researcher on Khmer architecture, adding that Vann Molyvann was the first of a new generation of Khmer architects to "use new methods which made the buildings look good as well as serving the right functions."

Darryl Collins, an independent researcher and architecture historian, said that Khmer architecture has changed significantly over the years. There are four periods of Khmer architecture: local Khmer architecture (from the Angkor empire to 1863), French colonial architecture (1863-1953), New Khmer architecture (1953-1970) and contemporary architecture. What remains to be seen is whether or not contemporary architects can learn from their predecessors and design buildings that maintain elements of traditional Khmer styles.

As Phnom Penh and other urban centres develop in the coming decades, it will be architecture students like Loy Bunleng who decide exactly how to preserve Cambodia's much-celebrated architectural history in the bigger and more modern buildings being constructed.

Despite the fact that many of the major construction projects in Cambodia are being designed by foreign architects, Hok Sokol said that a renewed effort by the Ministry of culture to train highly skilled architects would help preserve Cambodia's aesthetic identity in the decades to come.

"There is no need to worry," he said. "We will not lose Khmer identity in the modern architectural designs because there are a number of proud Cambodian architects who will be sure to include Khmer styles into their creations before they begin building." LIFT

**ស៊ុន ណារិន, ទូច សុពណ៌ និង ង៉ោ ម៉េងហួង**

សំណង់ក្នុងប្រទេសកម្ពុជា បានរីកដុះដាលនៅសតវត្សរ៍ចុងក្រោយនេះ ហើយទោះបីជាមានវិបត្តិសេដ្ឋកិច្ច ការអភិវឌ្ឍប្រទេសនៅតែបន្តទៅមុខ។ ទោះបីជាមានការរីកចម្រើនដែលមិនធ្លាប់មាននៅក្នុងប្រទេសកម្ពុជា នាសតវត្សរ៍ចុងក្រោយ ក៏អគារជាច្រើនត្រូវបានរចនាឡើង ដោយជនបរទេស ដែលធ្វើឲ្យស្ថាបត្យករ និងប្រវត្តិវិទូខ្មែរ មានការព្រួយបារម្ភថា អគារទំនើបៗបច្ចុប្បន្នខ្វះរចនាប័ទ្មខ្មែរ និងធ្វើឲ្យទីក្រុងបាត់បង់អត្តសញ្ញាណជាតិ។

លោក ជា ប៊ុនសៀង ជានាយកផ្នែកស្ថាបត្យករនៃ Bunseang Architect and Associates បានមានប្រសាសន៍ថា ស្ថាបត្យកម្មកម្ពុជានៅខ្វះខាតជំនាញ និងបទពិសោធដោយសារតែកម្មវិធីសិក្សានៅក្នុងសាលាស្ថាបត្យកម្ម នៅកម្ពុជាចាស់ហួសសម័យ, កង្វះខាតលេខកូដអគារ និងតំបន់ ព្រមទាំងកង្វះខាតការណែនាំជំនាញពីវិស័យស្ថាបត្យកម្ម ឬក៏ពីក្រុមហ៊ុនស្ថាបត្យកម្មដែលដើរតួជាអ្នកគាំទ្រការងារស្ថាបត្យកម្ម នៅក្នុងវិស័យសាធារណៈ និងឯកជន។

លោកឡុយ ប៊ុនឡេង ជានិស្សិតស្ថាបត្យកម្មឆ្នាំទី៤ នៅសាកលវិទ្យាល័យន័រតុន បានឲ្យដឹងថា លោកមានការព្រួយបារម្ភពីការគូរប្លង់អគារផ្សេងៗដោយជនបរទេសច្រើនពេក។ គាត់បានឲ្យយោបល់ថា រាជរដ្ឋាភិបាលគួរតែ «លើកទឹកចិត្តវិស្វករខ្មែរ ដោយផ្តល់ឱកាសឲ្យពួកគេបញ្ចេញគំនិតពីព្រោះពួកយើងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគូរប្លង់ល្អបាន»។

ក្រៅពីបាត់បង់ឱកាសបង្ហាញជំនាញរបស់ពួកគេ កង្វះខាតនូវស្ថាបត្យករខ្មែរក្នុងការរចនាម៉ូដអគារថ្មីៗ ក៏ប្រហែលជាធ្វើឲ្យបាត់បង់អត្តសញ្ញាណខ្មែរដែរ។ លោក តាំង សុចិត្តវិទូ ជាសាស្ត្រាចារ្យផ្នែកស្ថាបត្យកម្មនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានបកស្រាយថា៖«ពួកយើងចង់បានអគារ ជាពិសេសអគាររដ្ឋ ដើម្បីតំណាងវប្បធម៌ខ្មែរ»។ លោកបន្តទៀតថា ដោយជនបរទេសមានការយល់ដឹងតិចតួចពីស្ថាបត្យកម្មខ្មែរ ស្ថាបត្យករខ្មែរមានរចនាប័ទ្មច្បាស់លាស់ដែលតំណាងឲ្យអត្តសញ្ញាណខ្មែរ។ លោកបន្ថែមថា៖«ពួកយើងមានការច្នៃប្រឌិត និងរក្សាប្រភពអត្តចរិតខ្មែរ។ ខ្ញុំចង់ឲ្យស្ថាបត្យករយើង បង្ហាញពីទេពកោសល្យរបស់ពួកគេដូចលោក វណ្ណ ម៉ូលីវណ្ណជាដើម»។

លោក វណ្ណ ម៉ូលីវណ្ណ ជាអ្នកបង្កើតស្ថាបត្យកម្មខ្មែរថ្មីដែលកើតឡើង នៅក្នុងសម័យអាណានិគមន៍បារាំងនៅក្នុងអំឡុងឆ្នាំ១៩៥០ ហើយក៏ជាស្ថាបត្យករដ៏ល្បីល្បាញជាងគេនៅប្រទេសកម្ពុជា នាសម័យបច្ចុប្បន្នដែរ។

នៅអំឡុងប្រាំទសវត្សរ៍ចុងក្រោយនេះ គាត់បានរចនាអគារគួរឲ្យកត់សម្គាល់ជាច្រើន នៅក្នុងទីក្រុងភ្នំពេញ។ អគារមួយចំនួនដូចជា វិមានឯករាជ្យមានលក្ខណៈដូចស្ថាបត្យកម្មខ្មែរបុរាណ។ ចំណែកឯ សាលសន្និសីទចតុមុខ ឬពហុកីឡដ្ឋានជាតិអូឡាំពិក មានទ្រង់ទ្រាយជាការរចនាបែបទំនើប និងលក្ខណៈខ្មែរ។

លោក វណ្ណ ម៉ូលីវណ្ណ គឺជាស្ថាបត្យករខ្មែរម្នាក់ ក្នុងចំណោមស្ថាបត្យករជាច្រើនដែល បានយកការរចនា បែបទំនើប និងបុរាណ បញ្ចូលគ្នា ដើម្បីបង្កើតម៉ូដទំនើប និងថែរក្សាប្រពៃណីដ៏ផូរផង់ និង ការដើរតួនាទីរបស់អគារបែបប្រពៃណី។ អាគារដឺប៉ាតឺម៉ង់បារាំង នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ត្រូវបានរចនាដោយ លោក វណ្ណ ម៉ូលីវណ្ណ គឺជាឧទាហរណ៍ជាក់ស្តែង។ ស្នាមភ្លោះ ដែលព័ទ្ធជុំវិញអគារមើលទៅគួរឲ្យទំនើប គឺជាសក្ការបូជាដល់ ស្នាមភ្លោះ ដែលស្ថិតនៅជុំវិញ ប្រាសាទអង្គរវត្ត និងប្រាសាទដទៃ។

លោក ហុក សុកល ស្ថាបត្យករខ្មែរ និង អ្នកស្រាវជ្រាវ បានថ្លែងថា ៖ «ប្រទេសដទៃមិនមានអគារបែបនេះទេ» ។ លោកបានបន្ថែមថា លោក វណ្ណ មូលីវណ្ណ គឺជាស្ថាបត្យករខ្មែរដំបូងនៃជំនាន់ថ្មី ដែលបានប្រើរបៀបថ្មី ក្នុងការរចនាអគារឲ្យមានសោភ័ណភាពស្អាត ហើយ ដើរតួនាទីយ៉ាងត្រឹមត្រូវ។

លោក ដារីល ខូលីន អ្នកស្រាវជ្រាវឯករាជ្យ និងជាប្រវិត្តវិទូស្ថាបត្យកម្ម បានថ្លែងថា បានផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ស្ថាបត្យកម្មខ្មែរមាន៤សម័យ គឺស្ថាបត្យកម្មខ្មែរក្នុងតំបន់ ( ពីសម័យអង្គរមកដល់ឆ្នាំ១៨៦៣ ) ស្ថាបត្យកម្មសម័យអាណានិគមបារាំង ( ១៨៦៣ ដល់ ១៩៥៣ ) ស្ថាបត្យកម្មខ្មែរទំនើប ( ១៩៥៣ ដល់ ១៩៧០ ) និងស្ថាបត្យកម្មសហសម័យ។ អ្វីដែលមើលឃើញនោះថា តើស្ថាបត្យករសហសម័យ អាចរៀនពីបុព្វាធិការី ដើម្បីរចនាអគារដែលអាចថែរក្សាធាតុនៃប្រពៃណីម៉ូដបុរាណ។

នៅពេលដែលទីក្រុងភ្នំពេញ ក៏ដូចជា មជ្ឈមណ្ឌលដទៃអភិវឌ្ឍនាទសវត្សរ៍ខាងមុខនេះ វាប្រាកដជាស្ថាបត្យករដូចជា លុយ ប៊ុនឡេង ដែលជាអ្នកនឹងសម្រេចនូវវិធីថែរក្សាប្រវិត្តសាស្ត្រស្ថាបត្យកម្មកម្ពុជាដ៏មានកិត្តិស័ព្ទ តាមរយៈអគារកាន់តែធំ និងទំនើប ដែលនឹងត្រូវកសាងឡើងព្រមទាំងបង្កើតស្ថាបត្យកម្មខ្មែរមួយកាន់តែថ្មី។

ទោះបីជាគម្រោងសាងសង់ធំៗជាច្រើន កំពុងត្រូវបានរចនាដោយស្ថាបត្យករបរទេសក៏ដោយ ក៏ ហុក សុកល ថ្លែងថាការប្រឹងប្រែងជាថ្មី របស់ក្រសួងវប្បធម៌ ដើម្បីបង្ហាត់ស្ថាបត្យករជំនាញជាន់ខ្ពស់ នឹងជួយថែរក្សាអត្តសញ្ញាណដ៏ផូរផង់របស់ខ្មែរនៅទសវត្សរ៍ខាងមុខ។ លោកបានថ្លែងថា ៖«មិនចាំបាច់ព្រួយបារម្ភទេ។ យើងនឹងមិនបាត់បង់អត្តសញ្ញាណខ្មែរនោះទេ នៅក្នុងការរចនាម៉ូដសំណង់អាគារបែបទំនើប ពីព្រោះមានស្ថាបត្យករខ្មែរមួយចំនួនដែលនឹងបញ្ចូលរចនាប័ទ្មខ្មែរមុនគេចាប់ផ្តើមសាងសង់អគារ»៕

**ប្រែសម្រួល: ឃី ហៃ និងគាំ ទីវា**


